M13/1/AXKHM/SP1/KHM/TZ0/XX

22130567

International Baccalaureate®
Baccalauréat International
Bachillerato Internacional

**KHMER A: LITERATURE – STANDARD LEVEL – PAPER 1**
**KHMER A : LITTÉRATURE – NIVEAU MOYEN – ÉPREUVE 1**
**KHMER A: LITERATURA – NIVEL MEDIO – PRUEBA 1**

Wednesday 8 May 2013 (morning)
Mercredi 8 mai 2013 (matin)
Miércoles 8 de mayo de 2013 (mañana)

1 hour 30 minutes / 1 heure 30 minutes / 1 hora 30 minutos

---

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Write a guided literary analysis on one passage only. In your answer you must address both of the guiding questions provided.
- The maximum mark for this examination paper is *[20 marks]*.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez une analyse littéraire dirigée d'un seul des passages. Les deux questions d'orientation fournies doivent être traitées dans votre réponse.
- Le nombre maximum de points pour cette épreuve d'examen est *[20 points]*.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Escriba un análisis literario guiado sobre un solo pasaje. Debe abordar las dos preguntas de orientación en su respuesta.
- La puntuación máxima para esta prueba de examen es *[20 puntos]*.


© International Baccalaureate Organization 2013

*សូមអ្នកធ្វើការវិភាគបែបអក្សរសិល្ប៍ទៅលើអត្ថបទ**មួយ**គត់។ ក្នុងចម្លើយរបស់អ្នក អ្នកត្រូវឆ្លើយតប នឹងសំណួរទាំងពីរដែលបានចោទសួរ។*

**1.**

នាងសេដ្ឋានិត្យឃើញម្ដាយប្រឹងតវ៉ាជាមួយឪពុកនាងសុមនាឡើងសសៃក ក៏លូកមាត់ឃាត់:

-ម៉ែប៉ុណ្ណឹងបានហើយ... នាំតែផ្អើលអ្នកផ្សារទេម៉ែ...

-ស្រីនិត្យមិនបាច់ឃាត់ម៉ែទេកូន... ម៉ែត្រូវតែនិយាយឱ្យអស់... ព្រោះតាប៉ិសំក្លូវហ្នឹង គុំនឹងម៉ែយូរហើយ... ហើយដើរបង្ខូចថាម៉ែរហាមនេះមកពីប៉ិនដើរខ្ជះខ្ជាយ... ថាម៉ែប៉ិនតត្រុកដើរខ្ចីបុលចងការគេឱ្យជុំទិស... មើល៍ៗតើខ្ញុំជំពាក់លុយអ្នកណាខ្លះ? ល្បងប៉ិត...? ល្បងនិយាយឱ្យក្មេងៗស្ដាប់ផងទៅមើលល្បងមាត់សំអុយ...! មាត់ត្មាត...!

ស្ត្រីលើកដៃចង្អុលមុខបុរសទាំងក្ដៅក្រហាយ ធ្វើឱ្យអ៊ុំប្រុសតតាំងមកវិញ:

-ចុះរហាមនេះមកពីស្អី...?! អញថាហ្នឹងខុសអ្ហែះ...? បើចំណាប់ម៉េចក៏មិនសង់វីឡាទិញឡានជិះទៅ...?! ហ្នឹងមកពីមារយាទមិនកើតដូចផេះកណ្ដាលចង្ក្រានបានជាគ្មានស្អីហក់លោតនឹងគេ... នេះប្រហែលជាបុណ្យជួយពេកហើយបានជាកន្ត្រកកន្ត្រាកអីចឹង...!

-ពុក...មីង...ឈប់ប្រកែកគ្នាទៅ...! មីង...ខ្ញុំសុំចិត្តមីង...សុំមីងអាណិតខ្ញុំផង...ពុកមីងចាស់ៗហើយ... ខ្ញុំមិនដឹងត្រូវធ្វើយ៉ាងម៉េចទេនេះ...

អ្នកគ្រូពេទ្យសុមនាប្រឹងនិយាយខាឃាំង រកកលស្រក់ទឹកភ្នែកបណ្ដាលឱ្យភ្ជួន តប់ប្រមល់ក្នុងចិត្ត ហើយនាងសេដ្ឋានិត្យជំរុះវាចាទាំងបង្ហាញមុខស្មើ:

-បើគិតតែគុំគួន ស្អប់ខ្ពើមគ្នា តើថ្ងៃណាទៅអាចរលាយអស់ភ្លើងគំនុំនោះ? ម៉ែក៏ដូចអ៊ុំ គិតតែចង់ឈ្នះរៀងៗខ្លួន... តើបានទៅលើអ្នកណា...? មានគំនុំ គួររំសាយទៅទើបសម...

-មែនហើយអ៊ុំ... សូម្បីផ្កាមាក់ប្រេងមាក់ប្រាងក៏មានក្លិនក្រអូបជាងផ្លែវាដែលទុំពណ៌លឿងដែរ... ឯសម្ដីក្មេងស្រុករក្រោយ ក៏អាចមានឱជារសព្រោះបានក្រេបសង្គម ជីវភាព តថភាពសង្គម ចិត្តសាស្ត្រ មនុស្សសាស្ត្របានរហ័សនិងលឿនជាងមនុស្សរសៀល... គួរអ៊ុំប្រើត្រចៀកស្ដាប់ផង ហើយកុំឱ្យគេថាមនុស្សសំដីស្រូវ គ្មានគ្រាប់ម្សៅអង្ករ នៅខាងក្នុង... មានរូបជាគ្រាប់ស្រូវនឹងគេដែរ តែគ្មានប្រយោជន៍ បែរជាប៉ើងហិចហើរតាមខ្យល់ទៅវិញ... អ៊ុំគួរគិតផងទៅ...!

កម្លោះជួយដាស់សតិអារម្មណ៍បុរសចំណាស់តាមភាសាទស្សនៈប្រាកដនិយមដូចជួយជំរុញឱ្យនាងសុមនាបញ្ឆោក់បន្ថែម:

-គេថា មនុស្សគេយកសម្ដី ដំរីគេយកភ្លុក ឯការមានមិនបីតំណ ឯក្រក៏មិនបីជាតិដែរ គួរពុកឈប់ប្រើគំនិតតុញតឿ តាមទស្សនៈទុទិដ្ឋនិយមទៅ អ្នកមីងបានសុខ ពុកបានសុខ យើងសុខសប្បាយទាំងអស់គ្នា ជាការល្អប្រពៃណាស់... ឬក៏ពុកភ្លេចអស់រលីងនូវពាក្យថា សក់អ្នកណាក្បាលអ្នកហ្នឹង... ស៊ីក្រាញ់ទាំងអាចម៍ ស៊ីច្រាច់ទាំងឫស និង ផ្អកក្រឹបស្អីគេនុ៎ះអស់ហើយ...?

អ៊ំប៊ុតក្ដៅចិត្តនឹងសម្ដីកូនស្រី ដែលខំបំបាក់មុខខ្លួនក៏ហើបសម្លេង:

-អញទះបែកមាត់ឥឡូវ ចេះហៃហៃចំណាប់ណាស់វ៉ី...! តស់ទៅផ្ទះ...! កុំឱ្យអញទើសត្រចៀកទៀត... មិនអីទេ... អញផ្ញើទុកសិនចុះនាងនិមល...

អ៊ុន សុខហ៊ាង, *ថ្ងៃមិនរុះរោយ* (១៩៩៨)

(ក) តើអ្នកនិពន្ធ មានសារអ្វីខ្លះចង់ផ្ដល់ឱ្យអ្នកអាន នៅក្នុងអត្ថបទនេះ?

(ខ) តើបច្ចេកទេសនៃការពិពណ៌នារបស់អ្នកនិពន្ធមានឥទ្ធិពលយ៉ាងដូចម្ដេចទៅលើអាកប្បកិរិយារបស់អ្នកអានចំពោះអត្ថបទនេះ? ចូរធ្វើការពិភាក្សា។

**2.**

## គួរតែដឹង

សួស្តីប្រិយមិត្រជិតនិងឆ្ងាយ
ខ្ញុំអភិប្រាយថ្លែងសេចក្តី
តាក់តែងកំណាព្យពាក្យកាព្យថ្មី
ប្រាប់ជនប្រុសស្រីនៃខ្លឹមសារ ។
ស្តីពីជីវិតនៃមនុស្សលោក
រស់នៅគគោកត្រូវសិក្សា
យុវជនយុវតីគ្រប់សាលា
ត្រូវប្រឹងសិក្សាគ្រប់វិជ្ជា ។
ត្រូវតែខិតខំកុំបណ្តោយ
ចំណេះនេះហើយជានាវា
ខំប្រឹងស្វះស្វែងកុំរួញរា
ដើម្បីវិជ្ជាយើងថ្លៃថ្លា ។
ម្នាក់ៗត្រូវប្រឹងគ្រប់នាទី
ដើម្បីជីវិតជាតិសាសនា
យើងជាកូនខ្មែរពូជឧស្សាហ៍
នោះទើបឈ្មោះថាស្នេហាជាតិ ។
ចំណេះចេះបានដោយសាររៀន
មិនមែនកើតមានដោយមិនឃ្លាត
ជីវិតកើតមកបានមួយជាតិ
ស៊ូលំបាកឃ្លាតព្រោះសិក្សា ។
យុវជនយុវតីខ្លះផ្សេងទៀត
មិនបានខ្មីឃ្មាតពិចារណា

រហូតដល់ភ្លេចការសិក្សា
ប្រព្រឹត្តអានាចារឥតគប្បី ។
លេងល្បែងពាលាច្រើនអនេក
ដែលជាចំណែកខុសប្រពៃ
ឆបោកលួចប្លន់ឥតប្រណី
ដោយគ្មានមេត្រីចិត្តករុណា ។
អ្នកអើយភ្ញាក់ឡើងទាន់នូវក្មេង
កុំឈ្លក់វង្វេងដោយតណ្ហា
ត្រូវតែលះបង់ក្នុងកាយា
អកុសលណាដែលទុច្ចរិត ។
ប្រទេសជាតិរុងរឿងទៅបាន
ត្រូវការធនធានមនុស្សចេះពិត
ពួកយើងគ្រប់គ្នាត្រូវតែគិត
មួយជីវិតពិតមានខ្លឹមសារ ។
មនុស្សយើងគ្រប់រូបរាល់គ្នា
ដែលមានវិជ្ជាក្នុងកាយា
ទើបអាចជួយជាតិនិងសាសនា
ហើយនិងគ្រួសារខ្លួនឧត្តម ។

ជា កែវមុនីជោតិ, *កម្រងកំណាព្យអមតៈបែបសង្គម និង ស្នេហា* (២០០៣)

(ក) តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចខ្លះចំពោះអត្ថបទកាព្យនេះ?

(ខ) ចូរធ្វើការពិភាក្សាទៅលើសារៈសំខាន់នៃចំណងជើងរបស់កំណាព្យចំពោះអត្ថន័យទាំងមូលនៃអត្ថបទកាព្យនេះ។